ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ០៨ សរា

# សារាចរ
# ស្តីពី
# ការរៀបចំខួបលើកទី៧៧ទិវាកុមារអន្តរជាតិ១មិថុនា ខួបលើកទី២៥ទិវាពិភពលោកប្រឆាំងពលកម្មកុមារ១២មិថុនា និងទិវាកុមារកម្ពុជាឆ្នាំ២០២៦

ព្រះរាជាណាចក្រកម្ពុជាតែងតែប្រារព្ធទិវាកុមារអន្តរជាតិ១មិថុនា ទិវាពិភពលោកប្រឆាំងពលកម្មកុមារ១២មិថុនា និងទិវាកុមារកម្ពុជា ដើម្បីរម្លឹកដល់ការអនុវត្តសិទ្ធិជាមូលដ្ឋានរបស់កុមារ និងបង្ហាញពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលចំពោះកុមារ ស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា អនុសញ្ញាស្តីពីសិទ្ធិកុមាររបស់អង្គការសហប្រជាជាតិ អនុសញ្ញារបស់អង្គការអន្តរជាតិខាងការងារលេខ១៨២ ស្តីពីការហាមប្រាមនិងសកម្មភាពបន្ទាន់សម្រាប់លុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ព្រមទាំងលិខិតបទដ្ឋានគតិយុត្តជាតិនិងលិខិតូបករណ៍អន្តរជាតិស្តីពីសិទ្ធិកុមារផ្សេងៗទៀត។

ការប្រារព្ធទិវាកុមារអន្តរជាតិ១មិថុនា គឺដើម្បីរម្លឹកដល់ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រដ៏សែនខ្លោចផ្សាឆ្នាំ១៩៤២-១៩៤៤ ក្នុងអំឡុងសង្គ្រាមលោកលើកទី២ ដែលកងទ័ពហ្វាស៊ីសអាល្លឺម៉ង់ បានកាប់សម្លាប់ស្ត្រីនិងកុមារយ៉ាងរង្គាលនៅភូមិលីឌីសែ នៃប្រទេសឆេកូស្លូវ៉ាគី និងភូមិអូរ៉ាឌួរ នៃប្រទេសបារាំង។ ទន្ទឹមនឹងនេះ ទិវានេះត្រូវបានបង្កើតឡើងក្នុងគោលបំណងលើកកម្ពស់ការការពារសិទ្ធិកុមារ ទប់ស្កាត់រាល់អំពើហិង្សា និងរួមគ្នាថែរក្សាសន្តិភាពពិភពលោក ដើម្បីធានាឱ្យកុមារគ្រប់រូបរស់នៅក្នុងសុខសុវត្ថិភាពនិងការអភិវឌ្ឍ។

ការប្រារព្ធទិវាពិភពលោកប្រឆាំងពលកម្មកុមារ១២មិថុនា គឺជាយុទ្ធនាការនិងចលនាប្រជាជាតិសកល ដើម្បីលើកកម្ពស់ការយល់ដឹងនិងកៀរគរការគាំទ្រពីសាធារណជន ក្នុងដំណើរឆ្ពោះទៅរកការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ ដែលបានស្តែងឱ្យឃើញតាមរយៈការផ្តល់សច្ចាប័នដោយប្រទេសជាច្រើនលើសកលលោក លើអនុសញ្ញារបស់អង្គការអន្តរជាតិខាងការងារលេខ១៨២ ស្តីពីការហាមប្រាមនិងសកម្មភាពបន្ទាន់សម្រាប់ការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ និងអនុសញ្ញានៃអង្គការអន្តរជាតិខាងការងារលេខ១៣៨ ស្តីពីការកម្រិតអាយុអប្បបរមាសម្រាប់ការចូលធ្វើការងារ សំដៅទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារក្នុងទម្រង់ធ្ងន់ធ្ងរ ជាអាទិ៍ទាសករកុមារ ការជួញដូរកុមារ ពេស្យាចារកុមារ និងការប្រើប្រាស់កុមារក្នុងជម្លោះប្រដាប់អាវុធនិងក្នុងស្ថានភាពងាយរងគ្រោះ។

ដោយឡែក ព្រះរាជាណាចក្រកម្ពុជាប្រារព្ធទិវាកុមារអន្តរជាតិ១មិថុនា និងទិវាកុមារកម្ពុជានេះឡើង ដើម្បីលើកកម្ពស់សុខុមាលភាព សុវត្ថិភាព និងការអភិវឌ្ឍកុមារ ព្រមទាំងការពារកុមារពីការរំលោភបំពានគ្រប់រូបភាព។ ជាពិសេស ទិវានេះក៏រម្លឹកនូវមហាវិនាសកម្មដ៏ធ្ងន់ធ្ងរ ដែលបង្កឡើងដោយរបបប្រល័យពូជសាសន៍

ប៉ុល ពត ដែលកាលនោះកុមារត្រូវបានបំបិទសិទ្ធិសេរីភាពទាំងស្រុង ទទួលរងនូវការកាប់សម្លាប់ ការធ្វើទារុណកម្ម ការបង្ខំឱ្យធ្វើការជាទម្ងន់ ការបង្អត់អាហារ និងការរស់នៅយ៉ាងលំបាកវេទនាដោយអយុត្តិធម៌ ព្រមទាំងបានបន្សល់ទុកនូវផលវិបាកយ៉ាងធ្ងន់ធ្ងរបំផុត។ ក្រោយថ្ងៃរំដោះ ៧ មករា ១៩៧៩ សិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ ជាពិសេស សិទ្ធិកុមារត្រូវបានស្តារនិងការពារយ៉ាងខ្ជាប់ខ្ជួន ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញ ច្បាប់ យុទ្ធសាស្ត្រចតុកោណ យុទ្ធសាស្ត្របញ្ចកោណ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ក្របខ័ណ្ឌគោលនយោបាយ កម្មវិធីនយោបាយ និងផែនការសកម្មភាពជាតិរបស់រាជរដ្ឋាភិបាល ដើម្បីធានានូវឧត្តមប្រយោជន៍របស់កុមារគ្រប់រូប។

ដើម្បីអបអរសាទរខួបលើកទី៧៧ទិវាកុមារអន្តរជាតិ១មិថុនា ខួបលើកទី២៥ទិវាពិភពលោកប្រឆាំងពលកម្មកុមារ១២មិថុនា និងទិវាកុមារកម្ពុជាឆ្នាំ២០២៦នេះ រាជរដ្ឋាភិបាលសូមដាក់ចេញនូវវិធានការណែនាំដូចខាងក្រោម៖

១- ខួបលើកទី៧៧ទិវាកុមារអន្តរជាតិ១មិថុនា ខួបលើកទី២៥ទិវាពិភពលោកប្រឆាំងពលកម្មកុមារ១២មិថុនា និងទិវាកុមារកម្ពុជាឆ្នាំ២០២៦ ត្រូវប្រារព្ធក្រោមប្រធានបទ **«សន្តិភាពជាមូលដ្ឋានគ្រឹះនៃការគោរព និងកិច្ចគាំពារសិទ្ធិកុមារ»** និង **«ប្តេជ្ញាលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារនៅគ្រប់ខ្សែច្រវាក់ផលិតកម្ម ដើម្បីកសាងភាពធន់និងការងារសមរម្យ»**។

២- ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងអប់រំ យុវជន និងកីឡា គណៈកម្មាធិការរៀបចំបុណ្យជាតិ-អន្តរជាតិ រដ្ឋបាលរាជធានីភ្នំពេញ និងស្ថាប័នពាក់ព័ន្ធ ត្រូវសហការរៀបចំមីទ្ទីងថ្នាក់ជាតិនិងរៀបចំកម្មវិធីកម្សាន្តផ្សេងៗសម្រាប់កុមារ នៅរាជធានីភ្នំពេញ។

៣- ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារថ្នាក់រាជធានី ខេត្ត ត្រូវសហការជាមួយមន្ទីរ អង្គភាពពាក់ព័ន្ធ និងដៃគូអភិវឌ្ឍ រៀបចំពិធីអបអរសាទរខួបលើកទី៧៧ទិវាកុមារអន្តរជាតិ១មិថុនា ខួបលើកទី២៥ទិវាពិភពលោកប្រឆាំងពលកម្មកុមារ១២មិថុនា និងទិវាកុមារកម្ពុជាឆ្នាំ២០២៦ នៅតាមមូលដ្ឋានរបស់ខ្លួនឱ្យបានផុលផុស។

៤- ក្រសួងព័ត៌មានត្រូវសហការជាមួយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ណែនាំប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ ឯកជន និងបណ្តាញសារព័ត៌មានសង្គមនានា ធ្វើការផ្សព្វផ្សាយដល់សង្គមជាតិទាំងមូល ឱ្យជ្រួតជ្រាបពីប្រវត្តិនិងគោលបំណងនៃទិវាកុមារអន្តរជាតិ១មិថុនា ទិវាពិភពលោកប្រឆាំងពលកម្មកុមារ១២មិថុនា និងទិវាកុមារកម្ពុជាឆ្នាំ២០២៦។

៥- គ្រប់ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត ត្រូវរៀបចំពិធីមីទ្ទីង ពិធីជួបសំណេះសំណាលជាមួយកុមារ កម្មវិធីកម្សាន្តសប្បាយរបស់កុមារ នៅតាមក្រសួង ស្ថាប័ន រាជធានី ខេត្ត គ្រឹះស្ថានសិក្សារដ្ឋនិងឯកជន អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនិងបរទេស និងគ្រប់មណ្ឌលកុមារកំព្រានៅក្នុងមូលដ្ឋានរៀងៗខ្លួន។

៦- គ្រប់ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត គ្រឹះស្ថានសាធារណៈនិងឯកជន ត្រូវជ្រើសរើសទីតាំងសមស្របដើម្បីចងបដាពាក្យស្លោកអបអរសាទរខួបលើកទី៧៧ទិវាកុមារអន្តរជាតិ១មិថុនា ខួបលើកទី២៥ទិវាពិភពលោកប្រឆាំងពលកម្មកុមារ១២មិថុនា និងទិវាកុមារកម្ពុជាឆ្នាំ២០២៦នេះ តាមខ្លឹមសារដូចខាងក្រោម៖

- ជយោ ព្រះរាជាណាចក្រកម្ពុជា!
- អបអរសាទរខួបលើកទី៧៧ទិវាកុមារអន្តរជាតិ១មិថុនា ខួបលើកទី២៥ទិវាពិភពលោកប្រឆាំងពលកម្មកុមារ១២មិថុនា និងទិវាកុមារកម្ពុជាឆ្នាំ២០២៦
- សន្តិភាពជាមូលដ្ឋានគ្រឹះនៃការគោរពនិងកិច្ចគាំពារសិទ្ធិកុមារ
- រួមគ្នាលើកកម្ពស់ការគោរពនិងការការពារសិទ្ធិកុមារឱ្យបានពេញលេញ
- កុមារកម្ពុជាចង់រស់នៅក្នុងសន្តិភាព ដោយទទួលបានការអប់រំនិងភាពរីករាយ
- កុមារគ្រប់រូបត្រូវការសន្តិភាពនិងទទួលបានការសិក្សាអប់រំ

- ការជួបជុំគ្រួសារ គឺជាម្លប់ដ៏កក់ក្ដៅបំផុតសម្រាប់កុមារគ្រប់រូប
- សិទ្ធិចូលរួម គឺជាការផ្ដល់តម្លៃលើសំឡេងរបស់កុមារ
- សន្តិភាព គឺជាគ្រឹះនៃសិទ្ធិរស់រានមានជីវិតនិងការអភិវឌ្ឍរបស់កុមារ
- ការគោរពសិទ្ធិគ្នាក្នុងពិភពឌីជីថល គឺជាកិច្ចការពារកុមារ
- សន្តិភាព គឺជាមូលដ្ឋានគ្រឹះនៃការអនុវត្តសិទ្ធិកុមារ
- រួមគ្នាគាំពារកុមារពីគ្រប់ទម្រង់នៃអំពើហិង្សា
- រួមគ្នាគាំពារកុមារក្នុងស្ថានភាពមានជម្លោះ
- ការពារកុមារកៀសសឹកពីអំពើហិង្សានិងការកេងប្រវ័ញ្ចផ្លូវភេទ
- សន្តិភាព គឺជាមូលដ្ឋានគ្រឹះដ៏ចាំបាច់ក្នុងការគាំពារកុមារគ្រប់រូប
- ផ្ដល់ស្នាមញញឹម ក្ដីសង្ឃឹម និងក្ដីស្រឡាញ់ដល់កុមារគ្រប់រូប
- រួមគ្នាលើកកម្ពស់ការអនុវត្តសិទ្ធិកុមារនិងផ្ដល់បរិយាកាសប្រកបដោយសុវត្ថិភាពដល់កុមារគ្រប់រូប
- រួមគ្នាកសាងសន្តិភាព ដើម្បីផ្ដល់ក្ដីសង្ឃឹមនិងសុខដុមរមនាដល់កុមារ
- រួមគ្នាលើកកម្ពស់លក្ខខណ្ឌការងារសម្រាប់កម្មករនិយោជិតវ័យក្មេង
- លុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារនៅថ្ងៃនេះ ដើម្បីទទួលបានការងារសមរម្យនៅថ្ងៃស្អែក
- គ្មានពលកម្មកុមារ នាំឱ្យសហគ្រាសមួយក្លាយជាសហគមន៍សុខសាន្តមួយ
- កុមារជាវ័យត្រូវសិក្សា មិនមែនជាវ័យត្រូវធ្វើការទេ
- អរគុណពុកម៉ែ ដែលបញ្ជូនកូនទៅសាលារៀន
- ការទប់ស្កាត់ពលកម្មកុមារ ជាទំនួលខុសត្រូវរួមរបស់គ្រួសារ និយោជក និងសង្គមទាំងមូល
- លើកកម្ពស់កិច្ចគាំពារសង្គម ដើម្បីលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ
- លើកកម្ពស់លក្ខខណ្ឌការងារសម្រាប់កម្មករនិយោជិតវ័យក្មេង ដើម្បីផលិតភាពនិងការងារសមរម្យក្នុងយុគសម័យឌីជីថល។

ទទួលបានសារាចរនេះ ទីស្ដីការគណៈរដ្ឋមន្ត្រី គ្រប់ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត ត្រូវផ្សព្វផ្សាយ និងអនុវត្តឱ្យមានប្រសិទ្ធភាពនិងដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃសុក្រ ១៣កើត ខែជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គ្រប់ក្រសួង ស្ថាប័ន
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ